www.kidworship.kr

# ចំណងជើង៖ បុរសសុំទាន ឡាសា


75Page

យូរណាស់មកហើយមានបុរសអ្នកមានម្នាក់ គាត់រស់នៅក្នុងផ្ទះដែលមានការរចនា ក្បាច់ក្បូរយ៉ាងល្អប្រណិត
គាត់ពាក់សំលៀកបំពាក់ថ្លៃៗ និងបរិភោគអាហារឆ្ងាញ់ៗជារៀងរាល់ថ្ងៃ
ការរស់នៅរបស់គាត់គឺជាការរស់នៅបែបជីវិតមួយដែលល្អប្រណិត។
បុរសអ្នកមានគាត់តែងតែហៅបណ្តាជន ដើម្បីទៅបរិភោគអាហារនៅឯផ្ទះរបស់គាត់ជារៀងរាល់ថ្ងៃ។
គាត់ពិតជាមានអំណរ សប្បាយរីករាយជាមួយនឹងរឿងទាំងអស់នេះណាស់
ប៉ុន្តែគាត់មិនបានទទួលជឿលើព្រះជាម្ចាស់នោះទេ គាត់បានរស់នៅសំរាប់តែខ្លួនរបស់គាត់តែប៉ុណ្ណោះ។

---


76Page

មានបុរសម្នាក់ទៀតគាត់គឺជាមនុស្សក្រីក្រគាត់ឈ្មោះ ឡាសា។ ឡាសាកើតដំបៅពេញខ្លួន
ហើយគាត់តែងតែដេកនៅមាត់ទ្វារបងខាងមុខផ្ទះរបស់បុរសអ្នកមាននោះ។ ឡាសា គាត់ពិតជាចង់បរិភោគ
កំទេចអាហារដែលជ្រុះពីលើតុរបស់អ្នកមាននោះណាស់។
ប៉ុន្តែដោយសារតែគាត់មានដំបៅពេញខ្លួនដូច្នេះហើយ គ្មាននរណាម្នាក់ចង់ប៉ះពាល់ឬក៏
រាប់អានជាមួយនឹងគាត់នោះទេព្រោះពួកគេគិតថាខ្លួនរបស់គាត់សុទ្ធតែដំបៅ សំលៀកបំពាក់រយ៉េរយ៉ាក
និងមានក្លិនមិនល្អ។

---


77Page

ប៉ុន្តែឡាសាគាត់មានជំនឿលើព្រះជាម្ចាស់ ហើយជំនឿរបស់គាត់គឺជាជំនឿមួយដ៏ស្មោះត្រង់បំផុត។
នៅថ្ងៃមួយ ឡាសាដែលជាអ្នកក្រគាត់បានស្លាប់បាត់ទៅ។ ទេវតាបានយាងមកហើយនាំលោកឡាសា
ទៅឯស្ថានបរមសុខ ហើយបានដាក់គាត់នៅក្នុងដៃរបស់លោកអប្រាហាំ ដែលជាអ្នកសរសើរតម្កើងព្រះ
និងជាបិតានៃសេចក្តីជំនឿ។

---


78Page

បន្ទាប់មកអ្នកមាននោះក៏បានស្លាប់ទៅដែរ គេបានយកសពរបស់គាត់ទៅបញ្ចុះក្នុងផ្នូរ។
គាត់បានធ្លាក់ទៅក្នុងស្ថានឃុំមនុស្សស្លាប់ ហើយគាត់បានរងនូវទារុណកម្មនិង ការឈឺចាប់ជាខ្លាំង។
គាត់បានស្រែកអង្វរដោយភាពឈឺចាប់ដើម្បីស្វែងរកអ្នកដែលអាចនឹងបន្តក់ទឹកឲ្យគាត់បាន។

---


79Page

នៅក្នុងពេលដែលគេកំពុងតែធ្វើទារុណកម្ម បុរសអ្នកមានបានមើលឃើញ ស្ថានបរមសុខពីចម្ងាយ
គាត់បានឃើញឡាសានៅទីនោះ គឺនៅក្បែរលោកអប្រាហាំដែលជាបិតានៃសេចក្តីជំនឿ។ ទេ..!
តើរឿងនេះកើតឡើងដោយរបៀបណា? បុរសអ្នកមានឃើញដូច្នេះគាត់មានការច្រណែននឹងឡាសា។
គាត់បានហៅទៅលោកអប្រាហាំ “លោកឪពុកអប្រាហាំ! សូមជួយកូនផង!!
ខ្លួនប្រាណខ្ញុំទាំងមូលកំពុងតែដុតដោយភ្លើង វាពិតជាក្តៅខ្លាំងណាស់!!
សូមលោកឪពុកបានប្រាប់ទៅដល់ឡាសាឲ្យយកម្រាមដៃជ្រលក់ក្នុងទឹក

លោកអប្រាហាំបានមានប្រសាសន៍ថា៖ “ឡាសាគេមិនអាចទៅកាន់កូនបានឡើយ
កូនអើយ!!ចូរនឹកចាំថាកាលកូននៅមានជីវិតនូវឡើយ កូនស្គាល់តែការសប្បាយ
រីឯឡាសាវិញគ្នាស្គាល់តែទុក្ខ។ឥឡូវនេះឡាសាគេបានសុខក្សេមក្សាន្តហើយ
តែកូនវិញត្រូវរងនូវភាពឈឺចាប់។ ម្យ៉ាងទៀតនៅទីនេះមានលំហរមួយយ៉ាងធំ ខណ្ឌយើងពីអ្នករាល់គ្នា
ទោះបីអ្នកណាម្នាក់ចង់ឆ្លងពីស្ថាននេះទៅរកអ្នករាល់គ្នា ក៏ឆ្លងមិនបានឡើយ ឬ
ទោះបីជាអ្នកណាម្នាក់ចង់ឆ្លងពីអ្នករាល់គ្នាមករកយើងក៏ឆ្លងមិនបានដែរ”។

---


80Page

នៅក្នុងពេលដ៏ក្រៀមក្រំនោះ បុរសអ្នកមានបានអង្វរទៅលោកអប្រាហាំថា៖ “លោកឪពុកអើយ!!
សុំលោកឪពុកមេត្តាចាត់ឡាសា ឲ្យទៅផ្ទះរបស់ឪពុករបស់ខ្ញុំផង ខ្ញុំមានបងប្អូនប្រាំនាក់។
សុំឲ្យឡាសាទៅប្រាប់ពួកគេឲ្យបានដឹងខ្លួន
ដើម្បីកុំឲ្យពួកគេធ្លាក់មកកន្លែងដែលមាននូវទារុណកម្មដ៏ឈឺចាប់ដូចជាខ្ញុំបែបដូច្នេះអី។
លោកអប្រាហាំបានឆ្លើយតបថា៖ “បងប្អូនរបស់កូនបានឮពាក្យប្រៀនប្រដៅ របស់លោកម៉ូសេនិង
ពាក្យប្រៀនប្រដៅរបស់ព្យាការីហើយ ដូច្នេះឲ្យពួកគេបានធ្វើតាមពាក្យទាំងនោះចុះ
បុរសអ្នកមានបានអង្វរដល់លោកអប្រាហាំម្តងទៀតថា៖ “ ទេ!
លោកឪពុកទាល់តែមាននរណាម្នាក់ពីក្នុងចំណោមមនុស្សស្លាប់ទៅប្រាប់ពួកគេ
ទើបពួកគេអាចកែប្រែចិត្តគំនិត និងទទួលជឿលើព្រះយេស៊ូ។
លោកអប្រាហាំក៏បានឆ្លើយតបទៅបុរសអ្នកមាននោះម្តងទៀតថា៖
ប្រសិនបើពួកគេមិនធ្វើតាមពាក្យប្រៀនប្រដៅរបស់លោកម៉ូសេ និងពាក្យប្រៀនប្រដៅរបស់ព្យាការីទេ
ទោះបីមានមនុស្សស្លាប់បានរស់ឡើងវិញ ទៅប្រាប់ពួកគេក៏ដោយក៏ពួកគេមិនព្រមទទួលជឿដែរ
ជាពិសេសគឺពួកគេមិនបានទទួលជឿលើព្រះយេស៊ូទៀត។ នៅពេលដែលអ្នកនៅរស់
គឺជាពេលដែលសំខាន់ណាស់ សំរាប់អ្នកក្នុងការកែប្រែចិត្តគំនិត និងស្តាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។
កាលដែលបុរសអ្នកមាន នៅរស់នៅឡើយគាត់មិនបានជួយដល់ឡាសាឡើយ
គាត់ពិតជាមិនស្គាល់អ្វីដែលជាសេចក្តីស្រឡាញ់ចំពោះអ្នកជិតខាងយ៉ាងពិតប្រាកដនោះទេ។

---


81Page

ដូចជាបុរសអ្នកមានម្នាក់នេះអញ្ចឹង ប្រសិនបើយើងមិនដឹងថា
យើងត្រូវស្រឡាញ់អ្នកជិតខាងរបស់យើងដោយរបៀបណានោះទេ
នោះយើងនឹងមិនអាចហៅថាជាបុត្ររបស់ព្រះជាម្ចាស់បានឡើយ។
ព្រះយេស៊ូបានបង្រៀនឲ្យយើង បានស្រឡាញ់ព្រះជាម្ចាស់ ហើយនិងស្រឡាញ់អ្នកជិតខាង
ឲ្យដូចជាស្រឡាញ់ខ្លួនឯងដែរ។